## **ជនរងគ្រោះ** (victim)

ជនរងគ្រោះ មានសិទ្ធិក្នុងការចូលរួមក្នុងនីតិវិធីតុលាការ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ។ ពីដើមមក ពួកគេគ្រាន់តែ ត្រូវបានស្តាប់ក្នុងនាមជាសាក្សី។ ក្រោយមកលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) បានធ្វើឲ្យប្រសើរជាងមុន ដោយអនុ ញ្ញាតឲ្យជនរងគ្រោះ បង្ហាញទស្សនៈ និងការបារម្ភ ក្នុងអំឡុងសវនាការ ដែលផលប្រយោជន៍របស់ពួកគេ ត្រូវបានប៉ះពាល់។

ការចូលរួមរបស់ជនរងគ្រោះនោះ អាស្រ័យតាមប្រព័ន្ធនៃនីតិវិធី។ ក្នុងប្រព័ន្ធដេញដោលតទល់ (adversary) ជនរងគ្រោះ មិនមានតួនាទីសកម្មទេ នេះដោយសារថា ផលប្រយោជន៍នៃរដ្ឋអាជ្ញា ស្រដៀងគ្នានឹងផលប្រយោជន៍នៃជនរងគ្រោះ។ ក៏ប៉ុន្តែ ការងាររបស់រដ្ឋអាជ្ញា គឺធ្វើយ៉ាងឲ្យការចោទ ប្រកាន់ ទទួលបាននូវជោគជ័យ ខុសពីប្រយោជន៍របស់ជនរងគ្រោះ។

ដូចបានបង្ហាញខាងលើ នីតិវិធីជាចម្បងរបស់ ICC ប្រកាន់តាមប្រព័ន្ធស៊ីវិលឡ ដោយអនុញ្ញាតឲ្យជនរងគ្រោះ ចូលរួម និងទទួលបានសិទ្ធិជាច្រើន ដូចជា សិទ្ធិត្រូវបានជូនដំណឹងពីការបិទការស៊ើបអង្កេត អាចដាក់យោបល់ ពាក់ព័ន្ធយុត្តាធិការ និង ការទទួលយកបាននៃបណ្តឹង (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 562-564)។

**ខ្លឹមសារបន្ថែម៖** ការចូលរួម និងសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានផ្តល់តម្លៃ និងចែងជាច្រើនក្នុង វិធានផ្ទៃក្នុងរបស់ អវតក ស្រដៀងគ្នានឹង លក្ខន្តិកៈរបស់ ICC។